រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

011KH01A-01

ព្រះឯកត្រីអង្គដ៏វិសុទ្ធ



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

១១

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

កិច្ចការរបស់ព្រះឯកត្រីអង្គ

ព្រះគម្ពីរបង្ហាញយ៉ាងច្បាស់ថា ព្រះជាម្ចាស់ជាព្រះតែមួយព្រះអង្គគត់ ។ «អ៊ីស្រាអែលអើយចូរស្តាប់ ! មានតែព្រះអម្ចាស់ជាព្រះរបស់យើងមួយព្រះអង្គគត់ ដែលពិតជាព្រះអម្ចាស់» (ទុតិយកថា ៦:៤) ហើយសូមអានអេសាយ ៤៤:៨ ផងដែរ ។ ប៉ុន្តែព្រះគម្ពីរបានបង្រៀនថែមទៀតថា ព្រះជាម្ចាស់គឺព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។

អង្គបីរបស់ព្រះឯកត្រីអង្គដ៏វិសុទ្ធ មិនអាចឃ្លាតចេញពីគ្នាបានទេ : គ្រប់កិច្ចការដែលព្រះអង្គធ្វើ ព្រះអង្គធ្វើរួមគ្នា ។ ព្រះអង្គជាព្រះតែមួយគត់ ។

ពាក្យ "ព្រះឯកត្រីអង្គ"
មានន័យថា ព្រះជាម្ចាស់ជា
ព្រះតែមួយដែលមានបី "អង្គ"

កំណត់ចំណាំ

© Project WorldReach © SEAN

កំណត់ចំណាំ

ព្រះឯកត្រីអង្គ និង ការបង្កើត

ព្រះគម្ពីរបានបង្ហាញថា អង្គនិមួយៗរបស់ព្រះឯកត្រីអង្គ គឺ ព្រះបិតា (១ កូរិនថូស ៨:៦) ព្រះបុត្រា (យ៉ូហាន ១:៣) និងព្រះវិញ្ញាណដ៏វិសុទ្ធ (កំណើតពិភពលោក ១:២) បានធ្វើកិច្ចការពេលបង្កើតសកលលោកទាំងមូល ។ ព្រះបុត្រាដែលជាព្រះបានគង់នៅតាំងពីមុនពេលព្រះអង្គចាប់កំណើតជាមនុស្សម្ល៉េះ :

«កាលពីដើមដំបូងបង្អស់
ព្រះជាម្ចាស់បានបង្កើត
ផ្ទៃមេឃ និងផែនដី»។

(កំណើតពិភពលោក ១:១)



«ដ្បិតព្រះជាម្ចាស់បានបង្កើតអ្វីៗ
សព្វសារពើក្នុងអង្គព្រះគ្រីស្ត » ។

(កូឡូស ១:១៦)

«ហើយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នៅរោរាពីលើផ្ទៃទឹក » ។
(កំណើត ពិភពលោក ១:២)

ព្រះឯកត្រីអង្គ និង
ការដែលព្រះយេស៊ូបានកើតមកជាមនុស្ស

ព្រះបិតាបានចាត់ព្រះបុត្រា អោយយាងមកក្នុងពិភពលោកនេះ ។ ព្រះបុត្រាបានចាប់កំណើតនឹងស្ត្រីព្រហ្មចារីយ៍ ឈ្មោះនាងម៉ារី ដោយសារឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ ។



«ព្រះវិញ្ញាណដ៏វិសុទ្ធ នឹងយាងមកសណ្ឋិតលើនាង គឺឫទ្ធានុភាពរបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុត នឹងគ្របបាំងនាង ។ ហេតុនេះ គេនឹងថ្វាយព្រះនាមដល់បុត្រដ៏វិសុទ្ធ ដែលត្រូវប្រសូតមកនោះថា "ព្រះបុត្រារបស់ព្រះជាម្ចាស់" » ។

(លូកា ១:៣៥)

មានព្រះជាម្ចាស់តែមួយគត់ ។ ហេតុនេះហើយបានជាអ្វីៗដែលព្រះអង្គធ្វើ ត្រូវតែជាប់ទាក់ទងនឹងអង្គទាំងបីរបស់ព្រះឯកត្រីអង្គ ដែលមិនអាចឃ្លាតចេញពីគ្នាបាន ។

ព្រះឯកត្រីអង្គ និង ក្រុមជំនុំជាព្រះសហគមន៍

ក្រុមជំនុំជាព្រះកាយរបស់ព្រះគ្រីស្ត ។ ព្រះគ្រីស្តជាអ្នកដឹកនាំក្រុមជំនុំ ។ ព្រះវិហារមិនមែនគ្រាន់តែជាអាគារប៉ុណ្ណោះទេ ក្រុមជំនុំជាមនុស្សទាំងអស់ដែលជឿ និងរួមជាមួយព្រះយេស៊ូគ្រីស្ត ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ។

**ព្រះយេស៊ូជាសិរសានៃព្រះកាយ
របស់ព្រះអង្គដែលជាក្រុមជំនុំ ។
យើងថ្វាយការសរសើរតម្កើង
ដល់ព្រះជាម្ចាស់ជាព្រះបិតា
តាមរយៈព្រះយេស៊ូគ្រីស្ត ។**

កិច្ចការដែលត្រូវអនុវត្ត

- បង្រៀនពីកិច្ចការធំៗរបស់ព្រះជាម្ចាស់ជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ដោយពន្យល់ថា អង្គទាំងបីរបស់ព្រះឯកត្រីអង្គមិនដែលបែកចេញពីគ្នា ហើយតែងតែធ្វើការរួមគ្នា ។ ជំរុញទឹកចិត្តក្រុមជំនុំអោយសរសើរតម្កើងព្រះ-ជាម្ចាស់ ដែលជាព្រះឯកត្រីអង្គ ។

© Project WorldReach © SEAN

ព្រះឯកត្រីអង្គ និង ពិធីជ្រមុជទឹករបស់ព្រះយេស៊ូគ្រីស្ត

យើងអាចឃើញអង្គទាំងបីរបស់ព្រះឯកត្រីអង្គ ដែលមិនអាចឃ្លាតចេញពីគ្នាបាន ក្នុងពេលដែលព្រះយេស៊ូទទួលពិធីជ្រមុជទឹក :

«ហើយព្រះវិញ្ញាណដ៏វិសុទ្ធយាងចុះមក មានរូបរាងដូចសត្វព្រាប សណ្ឋិតលើព្រះអង្គ ។ មានព្រះសូរសៀងពីលើមេឃមកថា៖ «ព្រះអង្គជាបុត្រដ៏ជាទីស្រឡាញ់របស់យើង យើងគាប់ចិត្តនឹងព្រះអង្គណាស់» ។

(លូកា ៣:២២)





ព្រះវិញ្ញាណបានយាងចុះមក មានរូបរាងដូចសត្វព្រាប ដើម្បីឱ្យគេអាចឃើញព្រះអង្គយាងមកសណ្ឋិតដែរ ។

មាសាតាំងអាចបណ្តាលអោយមនុស្សខ្លះ ចូលរួមជាមួយគ្រីស្តជន ទោះជាអ្នកទាំងនោះមិនបានកែប្រែចិត្តគំនិត និងកើតជាថ្មីក៏ដោយ ។ អ្នកទាំងនោះខ្លះ រង់ចាំឱ្យបានឃើញការអស្ចារ្យគើតមានសិន ទើបជឿទុកចិត្តលើព្រះយេស៊ូគ្រីស្ត (ម៉ាថាយ ១២:៣៨-៤២) ។ អ្នកខ្លះទៀតចាត់ទុកជំនឿលើព្រះគ្រីស្តជាសាសនាមួយ ហើយមានបំណងចង់ចូលរួមក្នុងសាសនានោះ ដោយមិនបានជឿទុកចិត្តលើព្រះយេស៊ូគ្រីស្តទេ ។ បានន័យថា ពួកគេថ្វាយខ្លួនក្នុងន័យចូលរួមក្នុងសាសនាមួយច្រើនជាង (ម៉ាថាយ ១៥:៧-៩) ។ ដូច្នេះ ព្រះវិញ្ញាណដ៏វិសុទ្ធមិនធ្វើកិច្ចការ ក្នុងចិត្តរបស់ពួកគេទាំងនេះទេ ។

- ព្រះវិញ្ញាណដ៏វិសុទ្ធជាព្រះជាម្ចាស់ដ៏វិសុទ្ធបំផុត ។ ដោយសារព្រះអង្គមានលក្ខណៈបែបនេះ ទើបការបានកើតជាថ្មីពិតតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ ធ្វើអោយយើងបានវិសុទ្ធពិត ។

  ការកែប្រែចិត្តគំនិតពិតប្រាកដ នៅស្ថិតស្ថេរឋូត ហើយមិនមែនជាអារម្មណ៍ ដែលចុះឡើងៗនោះទេ ។
  (២ កូរិនថូស ៣:១៨, រ៉ូម ៨:២៦-២៩)

ព្រះឯកត្រីអង្គ ការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូ :

ព្រះបុត្រាបានសុគតដើម្បីលោះបាបយើង គឺព្រះបុត្រាបានថ្វាយខ្លួនព្រះអង្គផ្ទាល់ទៅព្រះបិតា តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ :

«ចំណង់បើព្រះលោហិតរបស់ព្រះគ្រីស្តវិញ តើនឹងរឹតតែជំរុះមនសិការ យើងឱ្យបានរួចផុតពីអំពើឥតបានការ ដើម្បីគោរពបំរើព្រះជាម្ចាស់ដ៏មានព្រះជន្មរស់ខ្លាំងយ៉ាងណាទៅទៀត ? គឺដោយសារព្រះវិញ្ញាណដែលគង់នៅអស់កល្បជានិច្ច ព្រះគ្រីស្តបានថ្វាយព្រះអង្គផ្ទាល់ទៅព្រះជាម្ចាស់ទុកជាយញ្ញបូជាឥតសៅហ្មង»។
(ហេប្រឺ ៩:១៤)



«តែបើគិតជាព្រះវិញ្ញាណដែលផ្តល់អោយបានវិសុទ្ធវិញ ព្រះជាម្ចាស់បានតែងតាំងព្រះអង្គជាព្រះបុត្រាប្រកបដោយឫទ្ធានុភាព ដោយប្រោសព្រះអង្គអោយមានព្រះជន្មរស់ឡើងវិញ » ។ (រ៉ូម ១:៤)

ការប្រោសយើងអោយបានវិសុទ្ធ មានចំណុចផ្សេងៗដូចតទៅ :

- យើងទាំងអស់គ្នាដែលជឿលើព្រះគ្រីស្ត បានជ្រះស្អាតនៅចំពោះព្រះជាម្ចាស់ ដោយសារព្រះលោហិតរបស់ព្រះ-យេស៊ូ ។ ព្រះវិញ្ញាណដ៏វិសុទ្ធជំរះសំអាតយើង នៅពេលដែលយើងជឿ ។
  (កិច្ចការ ២:៣៨, ១ ករ. ១:២, ១ ពេត្រុស ១:២)
- បន្ទាប់មក ព្រះវិញ្ញាណដ៏វិសុទ្ធធ្វើអោយយើងបានគ្រប់លក្ខណៈបន្តិចម្តងៗក្នុងអង្គព្រះគ្រីស្ត ។ យើងរង់ចាំថ្ងៃនោះ គឺពេលដែលយើងនឹងបានគ្រប់លក្ខណ៍ប្រកបដោយសិរីរុងរឿង ដើម្បីអោយយើងអាចឃើញព្រះអង្គទល់មុខគ្នា ។
  (អេភេសូ ៤:១៣-១៥, ភីលីព ១:៦, ៣:១២-១, ១ យ៉ូហាន ៣:២-៣)

«អ្នករាល់គ្នាត្រូវតែវិសុទ្ធ ព្រោះយើងវិសុទ្ធ » ។ *(១ ពេត្រុស ១:១៦)*



«ព្រះជាម្ចាស់ជាព្រះបិតាបានជ្រើសរើសបងប្អូន តាមគំរោងការដែលព្រះអង្គគ្រោងទុកពីមុន ដោយ ព្រះវិញ្ញាណប្រោសបងប្អូនអោយបានវិសុទ្ធ ដើម្បីអោយបងប្អូនស្តាប់បង្គាប់ព្រះយេស៊ូគ្រីស្ត និងអោយព្រះអង្គប្រោសព្រះលោហិតរបស់ព្រះអង្គលើបងប្អូន » ។ *(១ ពេត្រុស ១:២)*

ព្រះឯកត្រីអង្គ និងការធ្វើអោយមនុស្ស ទទួលស្គាល់ថាខ្លួនមានបាប

ព្រះវិញ្ញាណធ្វើអោយមនុស្សដឹងថា គេជាមនុស្សបាប ។ នៅពេលដែលមនុស្សជឿលើព្រះយេស៊ូគ្រីស្ត ហើយព្រះអង្គបានរាប់គេជាអ្នកសុចរិតហើយនោះ ព្រះបិតានឹងទទួលគេជាបុត្រធីតារបស់ព្រះអង្គដែរ ។

«រីឯព្រះដ៏ជួយការពារ ដែលខ្ញុំនឹងចាត់ពីព្រះបិតាអោយមករកអ្នករាល់គ្នា គឺជាព្រះវិញ្ញាណដែលសំដែងសេចក្តីពិត ព្រះអង្គចេញពីព្រះបិតាមក ។ កាលណាព្រះអង្គយាងមកដល់ទ្រង់នឹងធ្វើជាបន្ទាល់អំពីខ្ញុំ ។ ...កាលណាព្រះអង្គយាងមកដល់ព្រះអង្គនឹងបញ្ជាក់អោយមនុស្សលោកដឹងថា គេយល់ខុសអំពីបាប អំពីសេចក្តីសុចរិត និងអំពីការកាត់ទោស »។

(យ៉ូហាន ១៥:២៦, ១៦:៨)



«ដ្បិតព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាព្រះបន្ទូលដ៏មានជីវិត និងមានមហិទ្ធិឫទ្ធិ មុតជាងដាវមុខពីរទៅទៀត ។ ព្រះបន្ទូលនេះចាក់ទម្លុះចូលទៅកាត់ព្រលឹង និងវិញ្ញាណដាច់ចេញពីគ្នា កាត់សន្លាក់ឆ្អឹង និងខួរឆ្អឹងចេញពីគ្នា។ ព្រះបន្ទូលវិនិច្ឆ័យឆន្ទៈ និងគំនិតនៅក្នុងជំរៅចិត្តមនុស្ស »។

(ហេប្រឺ ៤:១២)

ព្រះឯកត្រីអង្គ និង ការជ្រោសយើងអោយបានវិសុទ្ធ

ព្រះបិតាបានបង្គាប់យើងថា យើងត្រូវតែវិសុទ្ធ ។ យើងបានសង្គ្រោះ ដោយសារការបូជាព្រះជន្មរបស់ព្រះយេស៊ូគ្រីស្ត ហើយបានវិសុទ្ធ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ។ ពេលបានសង្គ្រោះហើយ ព្រះអង្គនឹងគង់សណ្ឋិតនៅក្នុងយើង ហើយបំផ្លាស់បំប្រែយើងទាំងស្រុង ។ នៅពេលដែលយើងទទួលព្រះគ្រីស្ត ព្រះ-ជាម្ចាស់រាប់យើងជាសុចរិតគ្រប់លក្ខណ៍ ហើយវិសុទ្ធ ប៉ុន្តែយើងនៅតែត្រូវខិតខំកែប្រែទម្លាប់ចាស់ជាច្រើនរបស់យើង ហើយយកឈ្នះលើគំនិតខាងលោកីយ៍ (ខាងសាច់ឈាម) ។

ព្រះឯកត្រីអង្គ និង ការចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធ

ព្រះជាម្ចាស់ចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធ មកលើអស់អ្នកដែលជឿលើព្រះយេស៊ូគ្រីស្ត ។ « បងប្អូនពិតជាបុត្រធីតារបស់ព្រះជាម្ចាស់មែន ព្រោះព្រះអង្គបានចាត់ព្រះវិញ្ញាណនៃព្រះបុត្រារបស់ព្រះអង្គ អោយមកសណ្ឋិតក្នុងចិត្តយើង គឺព្រះវិញ្ញាណនេះហើយ ដែលបន្តឹព្រះសូរសៀងឡើងថា "អប្បា ! ឱព្រះបិតា !" »

(កាឡាទី ៤:៦)



« ព្រះអម្ចាស់មានព្រះបន្ទូលថា៖ "យើងនឹងចាក់បង្ហូរព្រះវិញ្ញាណរបស់យើងមកលើមនុស្សលោកទាំងអស់ ។ កូនប្រុសកូនស្រីរបស់អ្នករាល់គ្នានឹងថ្លែងព្រះបន្ទូល ពួកចាស់ទុំរបស់អ្នករាល់គ្នានឹងយល់សុបិននិមិត្ត ហើយពួកយុវជននឹងនិមិត្តឃើញការអស្ចារ្យ " » ។

(យ៉ូអែល ២:២៨)



« ព្រះជាម្ចាស់បានលើកលោកយេស៊ូឡើង ដោយឫទ្ធិបារមីរបស់ព្រះអង្គ។ លោកយេស៊ូបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធពីព្រះបិតា តាមព្រះបន្ទូល សន្យា ហើយចាក់បង្ហូរព្រះវិញ្ញាណនេះ មកលើយើងខ្ញុំ ដូចបងប្អូនបាន ឃើញ បានឮស្រាប់ » ។ (កិច្ចការ ២:៣៣)

ព្រះឯកត្រីអង្គ និង ការលើកលែងទោសអំពើបាបរបស់យើង តាមរយៈការសុគតរបស់ព្រះយេស៊ូគ្រីស្ត

« ព្រះជាម្ចាស់ (ព្រះបិតា) ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះ ហើយបានជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមក » ។

(យ៉ូហាន ៣:១៦)



« ដោយយើងរួមក្នុងអង្គព្រះគ្រីស្តនេះ ព្រះជាម្ចាស់បានលោះយើង ដោយព្រះលោហិតរបស់ព្រះអង្គ និងលើកលែងទោសយើងឱ្យបានរួចពីបាប តាមព្រះហឫទ័យប្រណីសន្តោសដ៏លើសលប់របស់ព្រះអង្គ » ។ (អេភេសូ ១:៧)

« ប៉ុន្តែព្រះជាម្ចាស់លាងសំអាតបងប្អូន ប្រោសប្រទានឱ្យបងប្អូនបានវិសុទ្ធ ព្រមទាំងឱ្យបងប្អូន បានសុចរិតក្នុងព្រះនាមព្រះអម្ចាស់យេស៊ូគ្រីស្ត តាមរយៈព្រះវិញ្ញាណនៃព្រះជាម្ចាស់របស់យើងរួចស្រេចហើយ »។

(១ កូរិនថូស ៦:១១)

ព្រះឯកត្រីអង្គ និង ការកើតជាថ្មី ខាងព្រលឹងវិញ្ញាណរបស់យើង

នៅពេលដែលយើងបានកើតជាថ្មីខាងព្រលឹងវិញ្ញាណភ្លាម យើងក៏បានសង្គ្រោះនៅពេលនោះភ្លាម ។ យើងកើតជាថ្មីនេះដោយសារកិច្ចការរបស់ព្រះឯកត្រីអង្គ គឺយើង :

- កើតពីព្រះជាម្ចាស់ដែលជាព្រះបិតា ។
  (យ៉ាកុប ១:១៧-១៨, យ៉ូហាន ១:១៣)
- កើតជាថ្មីដោយសារព្រះបុត្រា ។
  (១ ពេត្រុស ១:៣, ទីតុស ៣:៥-៦)
- កើតពីព្រះវិញ្ញាណដ៏វិសុទ្ធ ។
  (យ៉ូហាន ៣:៦, ទីតុស ៣:៥-៦)

យើងបានសង្គ្រោះដោយសារកិច្ចការរបស់ព្រះជាម្ចាស់តែមួយគត់ :

- ព្រះបិតាបានរៀបចំផែនការ ដើម្បីអោយយើងបានទទួលការសង្គ្រោះ ។
  (អេភេសូ ១:៣-៦)
- ព្រះបុត្រាធ្វើអោយផែនការនេះបានសំរេចដោយសារការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ ។ (រ៉ូម ៤:២៥)
- ព្រះវិញ្ញាណដ៏វិសុទ្ធអនុវត្តកិច្ចការរបស់ព្រះគ្រីស្តនៅក្នុង យើង ។
  (១ កូរិនថូស ៦:១១)

ការកើតជាថ្មីដែលនាំអោយ មានជីវិតអស់កល្បជានិច្ច

«សូមសរសើរតម្កើងព្រះជាម្ចាស់ ជាព្រះបិតារបស់ព្រះយេស៊ូគ្រីស្ត ជាព្រះអម្ចាស់នៃយើង ។ ព្រះជាម្ចាស់បានប្រោសយើងអោយកើតជាថ្មីដោយប្រោសព្រះយេស៊ូគ្រីស្តអោយមានព្រះជន្មរស់ឡើងវិញ ស្របតាមព្រះហឫទ័យមេត្តាករុណាដ៏លើសលប់របស់ព្រះអង្គ ដូច្នេះ យើងមានសេចក្តីសង្ឃឹម ដែលមិនចេះសាបសូន្យ » ។
(១ ពេត្រុស ១:៣)



«ព្រះអង្គក៏បានសង្គ្រោះយើង តាមព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ គឺមិនមែនមកពីយើងបានប្រព្រឹត្តអំពើសុចរិតនោះទេ ។ ព្រះអង្គសង្គ្រោះយើង ដោយលាងជំរះយើងអោយបានកើតជាថ្មី និងប្រទានអោយយើងមានជីវិតថ្មី ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ» ។ (ទីតុស ៣:៥)

© Project WorldReach © SEAN